ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ
CAMBODIAN NATIONAL COUNCIL
FOR CHILDREN

លេខ : ១២៩ ក.ជ.ក.ក

# សេចក្តីសំរេច
## ស្តីពី
## ការបង្កើតអនុគណៈកម្មការអភិវឌ្ឍកុមារតូច

## ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៥៦ អនក្របក ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ
- យោងតាមប្រការ ៤ នៃអនុក្រឹត្យលេខ ៥៦ អនក្របក ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ១៩៩៩ និង យោងតាមតំរូវការចាំបាច់នាពេលបច្ចុប្បន្ន ។
- តាមស្មារតីអង្គប្រជុំនៅអង្គការ Unicef ចុះថ្ងៃទី ៥ ខែ មិថុនា ឆ្នាំ ២០០២

## សំរេច

**ប្រការ១ .-**

បង្កើតអនុគណៈកម្មការអភិវឌ្ឍកុមារតូច សំរាប់ធ្វើការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីលើកកំពស់ការរស់រានការលូតលាស់ ការអភិវឌ្ឍន៍របស់កុមារ និង ការពារសិទ្ធិកុមារអោយមានសុខភាព អាហារូបត្ថម្ភ និង ការអភិវឌ្ឍន៍ជីវិតស្តង់ដាខ្ពស់បំផុត ដូចមានចែងក្នុងមាត្រា ៦ និង មាត្រា ២៤ នៃអនុសញ្ញា ស្តីពីសិទ្ធិកុមារ ។

ប្រការ ២ .-

សមាសភាពអនុគណៈកម្មការអភិវឌ្ឍកុមារតូច មានដូចខាងក្រោម :

| | |
|---|---|
| ១- ឯកឧត្តមអនុប្រធាន ក.ជ.ក.ក តំណាងក្រសួងសុខាភិបាល | ជាប្រធាន |
| ២- ឯកឧត្តមអនុប្រធាន ក.ជ.ក.ក តំណាងក្រសួងអប់រំ យុវជន និង កីឡា | ជាអនុប្រធាន |
| ៣-ប្រធានមជ្ឈមណ្ឌលជាតិគាំពារមាតា និង ទារក នៃក្រសួងសុខាភិបាល | ជាអនុប្រធានអចិន្ត្រៃយ៍ទី១ |
| ៤- ប្រធាននាយកដ្ឋានបឋម និង មត្តេយ្យសិក្សា នៃក្រសួងអប់រំ យុវជន និង កីឡា | ជាអនុប្រធានអចិន្ត្រៃយ៍ទី២ |
| ៥- មន្ត្រីតំណាងនាយកដ្ឋានសេដ្ឋកិច្ចសង្គម នៃក្រសួងផែនការ | ជាសមាជិក |
| ៦- មន្ត្រីតំណាងនាយកដ្ឋានថែទាំសុខភាពជនបទ នៃក្រសួងអភិវឌ្ឍន៍ជនបទ | ជាសមាជិក |
| ៧- មន្ត្រីតំណាងនាយកដ្ឋានសុខមាលភាពកុមារ នៃក្រសួងសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និង យុវនីតិសម្បទា | ជាសមាជិក |
| ៨- មន្ត្រីតំណាងនាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស នៃក្រសួងកិច្ចការនារី និង អតីតយុទ្ធជន | ជាសមាជិក |
| ៩- មន្ត្រីតំណាងនាយកដ្ឋានស្រាវជ្រាវជម្ងឺឆ្លង នៃក្រសួងសុខាភិបាល | ជាសមាជិក |
| ១០- នាយកកម្មវិធីអាហារូបត្ថម្ភនៃក្រសួងសុខាភិបាល | ជាសមាជិក |
| ១១- មន្ត្រីតំណាងនាយកដ្ឋានបណ្ដុះបណ្ដាល និង វិក្រឹតការ នៃក្រសួងអប់រំ | ជាសមាជិក |
| ១២- មន្ត្រីតំណាងនាយកដ្ឋានស្រាវជ្រាវ និង គរុកោសល្យ នៃក្រសួងអប់រំ | ជាសមាជិក |
| ១៣- មន្ត្រីតំណាងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ | ជាសមាជិក |
| ១៤- មន្ត្រីតំណាងអង្គការយូនីសេហ្វ | ជាជំនួយការបច្ចេកទេស |
| ១៥- មន្ត្រីតំណាងអង្គការយូណេស្កូ | ជាជំនួយការបច្ចេកទេស |
| ១៦- មន្ត្រីតំណាងអង្គការសុខភាពពិភពលោក | ជាជំនួយការបច្ចេកទេស |

ប្រការ ៣ .-

អនុគណៈកម្មការអភិវឌ្ឍន៍កុមារតូច មានភារកិច្ចទទួលខុសត្រូវ ដូចតទៅ :

១- សហការជាមួយក្រសួងពាក់ព័ន្ធដើម្បីវាយតម្លៃសភាពការនិងរៀបចំគោលនយោបាយ និង យុទ្ធសាស្ត្រជាតិ ស្ដីពីការអភិវឌ្ឍន៍កុមារតូច ។

២- ទាក់ទាញការគាំទ្រពីចំណោមអ្នកធ្វើគោលនយោបាយ អ្នកធ្វើសេចក្ដីសំរេចចិត្ត និង អ្នកធ្វើផែនការ ដើម្បីគាំទ្រដល់ការអភិវឌ្ឍន៍ និង ការអនុវត្តន៍គោលនយោបាយជាតិ ស្ដីពីការអភិវឌ្ឍន៍កុមារតូច ។

៣- ពិនិត្យតាមដាន និង ជំរុញសមាហរណកម្មនៃសកម្មភាពអភិវឌ្ឍកុមារតូចរបស់ក្រសួង និង ស្ថាប័នពាក់ព័ន្ធដើម្បីសំរេចបាននូវទិសដៅ និង គោលដៅ ។

៤- ធ្វើអនុសាសន៍ជូនក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការ និង កិច្ចសហការសំរបសំរួលរវាងក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការអនុវត្តន៍សកម្មភាពអភិវឌ្ឍកុមារតូច ។

៥- ធ្វើរបាយការណ៍ពិនិត្យតាមដាន ដែលជាកាតព្វកិច្ចតាមកាលកំណត់ និង ធ្វើរបាយការណ៍ស្តីពីការរីកចំរើន ក្នុងមួយឆ្នាំ ពីរដង ជូនដល់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ។

៦- ផ្លាស់ប្តូរ និង ចែកចាយពតិមាន សម្ភារៈ ឯកសារអប់រំ និង ទំនាក់ទំនង ព្រមទាំងគាំទ្រការប្រើប្រាស់នៅគ្រប់ជាន់ថ្នាក់ ។

៧- ជួយសំរួលការកសាងសមត្ថភាពរបស់ស្ថាប័នពាក់ពន្ធ័ ដើម្បីធ្វើផែនការ ដើម្បីអនុវត្ត និង ដើម្បីត្រួតពិនិត្យតាម-ដានសកម្មភាព សំដៅសំរេចបាននូវទិសដៅ និង គោលដៅជាតិនៃការអភិវឌ្ឍន៍កុមារតូច ។

៨- សហការជាមួយក្រុមការងារអប់រំសំរាប់ទាំងអស់គ្នា និង ក្រុមការងារ ឬ គណៈកម្មការផ្សេងទៀត ដែលទាក់-ទងនឹងការអភិវឌ្ឍន៍កុមារតូច ហើយធ្វើការកំណត់តំបន់ និង កិច្ចការជាទិភាព ដើម្បីកិច្ចសហប្រតិបត្តិការ ។

ប្រការ ៤ .-

អនុគណៈកម្មការអភិវឌ្ឍកុមារតូច មានការិយាល័យមួយស្ថិតនៅក្នុងអគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃក្រុមប្រឹក្សា-ជាតិកម្ពុជាដើម្បីកុមារ ។ ដំណើរការអនុគណៈកម្មការអភិវឌ្ឍកុមារតូច និង ប្រតិបត្តិតាមវិន័យការងារ និង បទបញ្ញត្តិផ្ទៃក្នុងដោយឡែករបស់ខ្លួន ។

ប្រការ ៥ .-

អនុគណៈកម្មការអភិវឌ្ឍកុមារតូច នឹងធ្វើការប្រជុំបីដងក្នុងមួយឆ្នាំ ដើម្បីពិនិត្យការរីកចំរើននៃការអភិវឌ្ឍន៍ និង ការអនុវត្តន៍គោលនយោបាយជាតិ ស្តីពីការអភិវឌ្ឍន៍កុមារតូច ហើយផ្តល់ការណែនាំសំរាប់សកម្មភាពលើកក្រោយទៀត ។

ប្រការ ៦ .-

អនុប្រធានអចិន្ត្រៃយ៍នៃអនុគណៈកម្មការអភិវឌ្ឍកុមារតូច នឹងធ្វើការប្រជុំក្រុមការងារបច្ចេកទេសរាល់ខែ ឬញឹកញាប់ តាមការចាំបាច់ ។

ប្រការ ៧ .-

តំណាងអង្គការជាតិ អង្គការក្រៅរដ្ឋាភិបាល និង ឯកត្តជនដែលចាប់អារម្មណ៍ នឹងត្រូវអញ្ជើញចូលរួមការប្រជុំរបស់

អនុគណៈកម្មការអភិវឌ្ឍកុមារតូច ក៏ដូចជាការប្រជុំរបស់ក្រុមការងារបច្ចេកទេស ។

<u>ប្រការ ៤</u> .-

សេចក្តីសំរេចនេះ មានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ, ថ្ងៃទី 13 ខែ វិច្ឆិកា ឆ្នាំ ២០០២

ជ. ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

ប្រធាន

[illegible] សំអោច

<u>ចំលងជូន</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អង្គការ និង ក្រសួងពាក់ព័ន្ធ
- កាលប្បវត្តិ - ឯកសារ